[ 03 ]

# Buddhism and the God-idea

***Q. Do Buddhist believe in god?***

A. No, we do not. There are several reasons for this. The Buddha, like modern sociologists and psychologists, believed that religious ideas and especially the god idea have their origin in fear. The Buddha says: "*Gripped by fear men go to the sacred mountains, sacred groves, sacred trees and shrines*". Dp 188

Primitive man found himself in a dangerous and hostile world, the fear of wild animals, of not being able to find enough food, of injury or disease, and of natural phenomena like thunder, lightning and volcanoes was constantly with him. Finding no security, he created the idea of gods in order to give him comfort in good times, courage in times of danger and consolation when things went wrong. To this day, you will notice that people become more religious at times of crises, you will hear them say that the belief in a god or gods gives them the strength they need to deal with life. You will hear them explain that they believe in a particular god because they prayed in time of need and their prayer was answered. All this seems to support the Buddha's teaching that the

ភាគ ៣

# ព្រះពុទ្ធសាសនាជាមួយនឹងគំនិតបូជាអាទិទេព

***បុ. តើពុទ្ធសាសនិកជនជឿលើអាទិទេពទេ?***

**វិ.** ទេ!យើងមិនជឿទេ។ មានហេតុផលច្រើនយ៉ាងអំពីរឿងនេះ។ ព្រះពុទ្ធជាម្ចាស់ប្រដូចជាអ្នកសង្គមវិទ្យានិងចិត្តវិទ្យាសម័យថ្មី ដែលជឿថាគំនិតខាងសាសនាហើយជាពិសេសជំនឿលើអាទិទេពមានប្រភពរបស់វាមកពីសេចក្តីភ័យខ្លាច។ព្រះពុទ្ធជាម្ចាស់ត្រាស់ថា "*ភ័យមកដល់មនុស្សទាំងឡាយយកភ្នំជាទីពឹងខ្លះ យកដំបូកជាទីពឹងខ្លះ យកដើមឈើនិងយកចេតិយ៍ជាទីពឹង*" ។ ទីឃនិកាយ ១៨៨

មនុស្សជំនាន់ដើមកសាងខ្លួនឯងក្រោមពិភពលោកនៃគ្រោះថ្នាក់និងការខ្លាចរអាភ័យខ្លាចសត្វព្រៃកំណាច មិនអាចរកអាហារហូបចុកគ្រប់គ្រាន់ ការឈឺចាប់ឬជំងឺផ្សេងៗ ហើយនឹងអព្ភូតហេតុខាងធម្មជាតិដូចជាផ្គរលាន់ វន្ទះបាញ់និងភ្នំភ្លើងផ្ទុះ ជានិច្ចជាកាលកើតឡើងដល់ពួកគេ។ ដោយពុំអាចរកសុវត្ថិភាពអ្វីផ្សេងបាន ពួកគេក៏បានបង្កើតគំនិតជឿលើអាទិទេពឡើងក្នុងគោលបំណងអោយគេបានសុខសប្បាយនៅពេលណាល្អ បន់ស្រន់អាទិទេពពេលជួបគ្រោះថ្នាក់ និងការបំពេរអារម្មណ៍ពួកគេពេលអ្វីគ្រប់យ៉ាងខុសពីប្រក្រតី។សព្វថ្ងៃនេះអ្នកអាចសង្កេតឃើញថាមនុស្សនឹងជឿលើអាទិទេពកាន់តែខ្លាំងនៅពេលណាជួបវិបត្តិ អ្នកនឹងឮពួកគេនិយាយថាគេជឿទៅលើឯកាទិទេពឬពហុអាទិទេពដែលជួយពង្រឹងតំរូវការពួកគេដើម្បីដោះស្រាយបញ្ហាជីវិត។ អ្នកនឹងឮពួកគេនិយាយពន្យល់យើងថា ពួកគេជឿលើអាទិទេពតែមួយអង្គគត់ព្រោះពួកគេបួងសួងពេលគេធ្លាក់ខ្លួនលំបាកហើយការបួងសួងរបស់គេត្រូវបានសំរេច។ ទាំងអស់នេះហាក់ដូចជាគាំទ្រពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលត្រាស់ថាទស្សនះជឿ

god-idea is a response to fear and frustration. The Buddha taught us to try to understand our fears, to lessen our desires and to calmly and courageously accept the things we cannot change. He replaced fear, not with irrational belief but with rational understanding.

The second reason the Buddha did not believe in a god is because there does not seem to be any evidence to support this idea. There are numerous religions, all claiming that they alone have god's words preserved in their holy book, that they alone understand god's nature, that their god exists and that the gods of other religions do not. Some claim that god is masculine, some that she is feminine and others that it is neuter. They are all satisfied that there is ample evidence to prove the existence of their god but they laugh in disbelief at the evidence other religions use to prove the existence of another god. It is not surprising that with so many different religions spending so many centuries trying to prove the existence of their gods that still no real, concrete, substantial or irrefutable evidence has been found. Buddhists suspend judgement until such evidence is forthcoming.

The third reason the Buddha did not believe in a god is that the belief is not necessary.

អាទិទេពគឺមកពីសេចក្ដីខ្លាចនិងសេចក្ដីមិនទុកចិត្តខ្លួនឯង។ ព្រះពុទ្ធជាម្ចាស់បង្រៀនយើងអោយព្យាយាមសិក្សាអោយយល់អំពីសេចក្ដីភ័យខ្លាចរបស់ខ្លួនឯង កាត់បន្ថយសេចក្ដីលោភលន់និងទទួលយកនូវវត្ថុទាំងឡាយដែលយើងមិនអាចផ្លាស់ប្ដូរបានដោយភាពស្ងប់ស្ងៀមនិងក្លាហាន។ ព្រះអង្គបំបាត់សេចក្ដីខ្លាចមិនមែនដោយជំនឿគ្មានហេតុផលទេ តែដោយសេចក្ដីយល់ដឹងដែលប្រកបដោយហេតុផល។

ហេតុផលទីពីរដែលព្រះពុទ្ធអង្គមិនសង្ឃឹមលើអាទិទេពពីព្រោះហាក់ដូចជាគ្មានអ្វីដែលជាភស្ដុតាងគាំទ្រនូវគំនិតនេះ។ មានសាសនាជាច្រើន ដែលអះអាងថាសាសនារបស់ពួកគេតែមួយគត់ដែលពាក្យពិតរបស់ព្រះជាម្ចាស់រក្សាបានល្អក្នុងគម្ពីរសក្ដិសិទ្ធិរបស់គេ មានតែគេម្នាក់គត់យល់នូវធម្មជាតិរបស់អាទិទេព ដែលព្រះរបស់គេមានពិតតែព្រះរបស់សាសនាអ្នកដទៃមានមិនពិតទេ។ អ្នកខ្លះពោលថាអាទិទេពគឺជាភេទប្រុស អ្នកខ្លះថានាងជាភេទស្រី និងអ្នកខ្លះទៀតពោលថាវាជាអភេទ។ ពួកគេពេញចិត្តថានេះគឺជាភស្ដុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់នូវការមានពិតនៃអាទិទេពរបស់ពួកគេ តែពួកគេសើចចំអកនូវការជឿខុសចំពោះភស្ដុតាងរបស់សាសនាដទៃ ដែលអធិប្បាយបញ្ជាក់នូវភាពមានពិតនៃអាទិទេពអង្គផ្សេងទៀត។ វាមិនគួរអោយភ្ញាក់ផ្អើល ជាមួយនឹងសាសនាផ្សេងៗគ្នាជាច្រើនចំណាយពេលមកច្រើនសតវត្សន៍ក្នុងការព្យាយាមបង្ហាញភស្ដុតាងវត្ថុមានពិតនៃអាទិទេពទាំងឡាយរបស់ពួកគេ ដែលនៅតែមិនពិត មិនឃើញជារូបធម៌ រកមិនឃើញនូវភស្ដុតាងដែលគួរអោយជឿទុកចិត្តនិងជាវិជ្ជមាន។ ពុទ្ធបរិស័ទនៅមន្ទិលសង្ស័យការសំរេចចិត្តដូច្នេះ ទាល់តែភស្ដុតាងពិតប្រាកដត្រូវបានគេយកមកបង្ហាញ។

ហេតុផលទី៣ ព្រះពុទ្ធជាម្ចាស់មិនជឿលើអាទិទេពព្រោះថាជំនឿនោះគឺមិនចាំបាច់

Some claim that the belief in a god is necessary in order to explain the origin on the universe. But this is not so. Science has very convincingly explained how the universe came into being without having to introduce the god-idea. Some claim that belief in god is necessary to have a happy, meaningful life. Again we can see that this is not so. There are millions of atheists and free-thinkers, not to mention many Buddhists, who live useful, happy and meaningful lives without belief in a god.

Some claim that belief in god's power is necessary because humans, being weak, do not have the strength to help themselves. Once again, the evidence indicates the opposite. One often hears of people who have overcome great disabilities and handicaps, enormous odds and difficulties, through their own inner resources, through their own efforts and without belief in a god. Some claim that god is necessary in order to give man salvation. But this argument only holds good if you accept the theological concept of salvation and Buddhists do not accept such a concept. Based on his own experience, the Buddha saw that each human being had the capacity to purify the mind, develop infinite love and compassion and perfect understanding. He shifted attention from the heavens to the heart and encouraged us to find solutions to our problems through self-understanding.

អ្នកខ្លះពន្យល់ថាជំនឿលើអាទិទេពគឺចាំបាច់ក្នុងគោលបំណងដើម្បីពន្យល់ប្រភពដើមនៃចក្រវាឡ តែបញ្ហានេះវាមិនពិតដូច្នោះទេ។វិទ្យាសាស្ត្របានពន្យល់យ៉ាងច្បាស់នូវវិធីដែលចក្រវាឡបានកើតជាសភាវៈដោយមិនចាំបាច់មានការទទួលស្គាល់ពីទ្រឹស្តីអាទិទេព។ អ្នកខ្លះអះអាងថាជំនឿលើអាទិទេពគឺចាំបាច់ធ្វើអោយជីវិតសុខសប្បាយនិងមានន័យ។ ដូចគ្នាដែរយើងអាចឃើញថាមិនមែនដូច្នេះឡើយ។មានអ្នកមិនជឿអាទិទេពនិងអ្នកគិតឥស្សរះរាប់លាននាក់ ដោយមិននិយាយដល់ពុទ្ធសាសនិកជនផង ដែលរស់នៅយ៉ាងមានប្រយោជន៍ មានសេចក្តីសុខ និងមានន័យ ដោយគ្មានជំនឿទៅលើអាទិទេពទាល់តែសោះ។

អ្នកខ្លះអះអាងថាជំនឿលើអំណាចអាទិទេពគឺចាំបាច់ពីព្រោះមនុស្សលោក ជាអ្នកទន់ខ្សោយមិនមានកំឡាំងគ្រប់គ្រាន់ដើម្បីជួយខ្លួនឯង។ ដូចគ្នាដែរ ភស្តុតាងបានចង្អុលប្រាប់ផ្ទុយគ្នាស្រឡះ។ជាញឹកញាប់ឮចំពោះតែមនុស្សដែលបានឈ្នះលើអសមត្ថភាពនិងការវិកលវិការ ការទាស់ទែងនិងផលវិបាកធំៗបាន តាមរយៈធនធានផ្ទៃក្នុងផ្ទាល់របស់ពួកគេ តាមរយៈសេចក្តីព្យាយាមផ្ទាល់របស់ពួកគេនិងដោយគ្មានជំនឿលើអាទិទេពសោះ។ អ្នកខ្លះអះអាងថាព្រះអាទិទេពគឺចាំបាច់ដើម្បីនាំមនុស្សទៅរកឥស្សរភាព។ តែការជជែកគ្នាដូច្នេះចាត់ថាល្អបាន ប្រសិនបើអ្នកទទួលស្គាល់យកទ្រឹស្តីឥស្សរភាពបែបទេវវិទ្យា ហើយពុទ្ធសាសនាមិនទទួលយកនូវទ្រឹស្តីដូច្នោះទេ។សំអាងលើបទពិសោធន៍របស់ព្រះអង្គផ្ទាល់ ព្រះពុទ្ធជាម្ចាស់បានមើលឃើញថាមនុស្សលោកម្នាក់ៗមានសមត្ថភាពដើម្បីសំអាតចិត្ត អភិវឌ្ឍន៍ករុណាធម៌និងមេត្តាធម៌ឥតព្រំដែន ព្រមទាំងការយល់បានយ៉ាងបរិបូរ។ ព្រះអង្គពង្រីកការយកចិត្តទុកដាក់ចាប់ពីឋានសួគ៌រហូតដល់បេះដូង ហើយលើកទឹកចិត្តយើងអោយស្វែងរកដំណោះស្រាយទាំងឡាយដើម្បីប្រឈមមុខនឹងបញ្ហាទាំងឡាយតាមរយៈការយល់ដោយខ្លួនឯង។

***Q. But if there are no gods how did the universe get here?***

A. All religions have myths and stories which attempt to answer this question. In ancient times, when many simply did not know, such myths were adequate, but in the 20th century, in the age of physics, astronomy and geology, such myths have been superseded by scientific fact. Science has explained the origin of the universe without recourse to the god-idea.

***What does the Buddha say about the origin of the universe?***

It is interesting that the Buddha's explanation of the origin of the universe corresponds very closely to the scientific view. In the Aganna Sutta, the Buddha described the universe being destroyed and then re-evolving into its present form over a period of countless millions of years. The first life formed on the surface of the water and again, over countless millions of years, evolved from simple into complex organisms. All these processes are without beginning or end, and are set in motion by natural causes.

***Q. You say there is no evidence for the existence of a god. But what about miracles?***

A. There are many who believe that miracles are proof of god's existence. We hear wild claims that a healing has taken place but we never get an independent testimony from a medical office or a surgeon.

***ឫ. តែបើគ្មានអាទិទេពទេ តើចក្រវាឡកើតឡើងនៅទីនេះបានយ៉ាងណា?***

**ឆ.** សាសនាទាំងអស់ មានរឿងនិទាននិងរឿងរ៉ាវដែលព្យាយាមឆ្លើយនូវសំណួរនេះ។ ក្នុងសម័យបុរាណពេលគេមិនដឹងរឿងដែលសាមញ្ញៗគេក៏លើកតំកើងរឿងព្រេងនេះឡើង តែក្នុងសតវត្សន៏ទី២០ ជាយុគសម័យនៃរូបវិទ្យា តារាសាស្រ្តនិងធរណីវិទ្យា រឿងព្រេងទាំងនោះត្រូវបានជំនួសដោយរឿងពិតនៃវិទ្យាសាស្រ្ត។ វិទ្យាសាស្រ្តបានពន្យល់កំណើតនៃចក្រវាឡដោយមិនសំអាងទៅលើប្រភពដើមនៃទស្សនះជឿលើអាទិទេពឡើយ។

***តើព្រះពុទ្ធត្រាស់ថាដូចម្តេចអំពីកំណើតរបស់ចក្រវាឡ?***

វាជារឿងគួរអោយចាប់អារម្មណ៏ដែលពាក្យពន្យល់ណែនាំរបស់ព្រះពុទ្ធអំពីកំណើតនៃចក្រវាឡទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងទស្សនះវិទ្យាសាស្រ្ត។ ក្នុងគម្ពីរអកញ្ញសូត្រ ព្រះពុទ្ធជាម្ចាស់អធិប្បាយថាលោករបស់យើងត្រូវបានបំផ្លាញ ហើយវិវត្តន៏កើតឡើងវិញក្នុងទំរង់បច្ចុប្បន្ននេះ ឆ្លងកាត់ថេរវេលារាប់លានលានឆ្នាំ។ ជីវិតដំបូងក៏បានករកើតឡើងនៅលើទឹក ហើយវិលងទៅអស់វេលារាប់លានលានឆ្នាំទៀតក៏បានវិវត្តពីទំរង់ជីវិតដែលសាមញ្ញទៅជាអវយវះដែលស្មុគស្មាញ។ ការវិវត្តន៏ទាំងនេះគឺមិនមានចំណុចចាប់ផ្តើមនិងចំណុចទីបញ្ចប់ឡើយ ហើយផ្លាស់ប្តូរទៅតាមទំរង់ហេតុបច្ច័យរបស់ធម្មជាតិ។

***ឫ. អ្នកនិយាយថាគ្មានភស្តុតាងការមានអាទិទេពពិតប្រាកដ។ ចុះអំពីបដិហារទាំងឡាយ?***

**ឆ.** មានមនុស្សជាច្រើនជឿថាបដិហារទាំងឡាយជាភស្តុតាងនៃវត្តមានអាទិទេព។ យើងឮការអះអាងដែលគួរអោយតក់ស្លុតថាគេបានព្យាបាលមនុស្សអោយជាពីឈឺ តែយើងមិនដែលបានទទួលការពិសោធន៏យ៉ាងសេរីពីក្រុមមន្ត្រីពេទ្យឬពេទ្យវះកាត់សោះ។

We hear second-hand reports that someone was miraculously saved from disaster but we never get an eye-witness account of what is supposed to have happened. We hear rumours that prayer straightened a diseased body or strengthened a withered limb, but we never see X-rays or get comments from doctors or nurses. Wild claims, second-hand reports and rumours are no substitute for solid evidence and solid evidence of miracles is very rare.

However, sometimes unexplained things do happen, unexpected events do occur. But our inability to explain such things does not prove the existence of gods. It only proves that our knowledge is as yet incomplete. Before the development of modern medicine, when people didn't know what caused sickness people believed that god or the gods sent diseases as a punishment. Now we know what causes such things and when we get sick, we take medicine. In time when our knowledge of the world is more complete, we will be able to understand what causes unexplained phenomena, just as we can now understand what causes disease.

***Q. But so many people believe in some form of god, it must be true.***

A. Not so. There was a time when everyone believed that the world was flat, but they were all wrong. The number of people who believe in an idea is no measure of

ហើយឮសេចក្តីរាយការណ៍ចាស់ៗថា មានអ្នកខ្លះត្រូវបានជួយជីវិតដោយភាពអស្ចារ្យពីគ្រោះមហន្តរាយ តែយើងមិនដែលឃើញផ្ទាល់នឹងភ្នែកនូវហេតុការណ៍អ្វីដែលគេឧបមាថាបានកើតឡើង។យើងឮពាក្យចចាមអារាមថាការបួងសួងអាចពុះជ្រែកទៅរកខ្លួនមនុស្សឈឺ ឬជួយតម្រឹងដែលពុកផុយ តែយើងមិនដែលឃើញគេឆ្លុះដោយពន្លឺអ៊ុលត្រាសាវ ឬបានទទួលការពន្យល់បញ្ជាក់ពីវេជ្ជបណ្ឌិតឬគ្រូពេទ្យណាមួយសោះ។ ការអះអាងដ៏មោះមុតនេះ ជាពាក្យចចាមអារាមនិងដំណឹងពីបុរាណនាយ មិនមានដាក់បង្ហាញភស្តុតាងច្បាស់លាស់ណាមួយ ហើយភស្តុតាងច្បាស់លាស់ខាងបដិហារពិតជាកំរមានណាស់។ ទោះជាយ៉ាងណា ពេលខ្លះវត្ថុដែលមិនអាចពន្យល់បានក៏អាចកើតឡើង ហេតុការណ៍ដែលគេមិនបានគិតទុកជាមុនក៏អាចលេចធ្លោរឡើងបាន។តែជាអសមត្ថភាពរបស់យើងដើម្បីពន្យល់ហេតុការណ៍ដូច្នេះមិនមែនចង្អុលបញ្ជាក់ពីការមានតួអាទិទេពពិតនោះទេ។វាចង្អុលបញ្ជាក់ប្រាប់យើងច្បាស់ថាចំណេះដឹងរបស់យើងគឺមានមិនគ្រប់គ្រាន់។មុនពេលពេទ្យសម័យថ្មីមានការអភិវឌ្ឍន៏ ពេលមនុស្សមិនដឹងអំពីអ្វីជាសាហេតុនៃជំងឺ មនុស្សក៏នាំគ្នាជឿថាអាទិទេពអង្គតែមួយឬអាទិទេពច្រើនអង្គបញ្ជូនមេរោគជំងឺមកដើម្បីដាក់ទោសទណ្ឌកម្ម។ ឥឡូវនេះយើងដឹងថាអ្វីជាសាហេតុនៃជំងឺទាំងនោះ ហើយពេលយើងឈឺ យើងនឹងលេបថ្នាំ។ ក្នុងពេលដែលចំណេះដឹងរបស់យើងអំពីលោកមានការអភិវឌ្ឍន៏ច្រើនឡើង យើងអាចនឹងយល់នូវអ្វីដែលជាសាហេតុនូវអព្ភូតហេតុដែលមិនអាចយល់បាន ដូចដែលឥឡូវនេះយើងអាចយល់នូវអ្វីដែលជាសាហេតុនៃជំងឺ។

***ប៉ុ. តែមនុស្សជាច្រើនជឿលើតួអង្គអាទិទេពបុរាណផ្សេងៗ នោះវាពិតជាមានពិត។***

**ទិ.** មិនពិតទេ។ មានពេលមួយជាពេលដែលមនុស្សជឿថាពិភពលោកមានរាងសំប៉ែត តែពួកគេទាំងអស់នោះជឿខុស។ ចំនួនមនុស្សដែលជឿលើការគិតណាមួយគឺគ្មានរង្វាស់វាស់

the truth or falsehood of that idea. The only way we can tell whether an idea is true or not is by looking at the facts and examining the evidence.

### *Q. So if Buddhists don't believe in gods, what do you believe in?*

A. We don't believe in a god because we believe in man. We believe that each human being is precious and important, that all have the potential to develop into a Buddha – a perfected human being. We believe that human beings can outgrow ignorance and irrationality and see things as they really are. We believe that hatred, anger, spite and jealousy can be replaced by love, patience, generosity and kindness. We believe that all this is within the grasp of each person if they make the effort, guided and supported by fellow Buddhists and inspired by the example of the Buddha. As the Buddha says:

> "*No one saves us but ourselves,*
> *No one can and no one may.*
> *We ourselves must walk the path,*
> *But Buddhas clearly show the way*".
>
> Dp 165

សេចក្តីពិតឬសេចក្តីមិនពិតនៃគំនិតនោះទេ។ វិធីតែម្យ៉ាងយើងអាចប្រាប់ថាតើការគិតនោះពិតឬមិនពិតដោយការសំឡឹងមើលហេតុការណ៍ពិតទាំងឡាយ ហើយត្រួតពិនិត្យនូវភស្តុតាងនោះ។

### *ស្ុ.ដូច្នេះបើពុទ្ធសាសនិកជនមិនជឿលើអាទិទេពទាំងឡាយ តើពុទ្ធសាសនិកជនជឿទៅលើអ្វី?*

**ទិ.** យើងមិនជឿលើអាទិទេពពីព្រោះយើងជឿលើមនុស្ស។ យើងជឿថាមនុស្សម្នាក់ៗគឺមានតំលៃនិងមានសារះប្រយោជន៏ ដែលមនុស្សទាំងអស់នោះមានសក្តានុពលដើម្បីអភិវឌ្ឍន៏ខ្លួនឯងអោយក្លាយជាព្រះសម្មាសម្ពុទ្ធជាម្ចាស់បាន ដែលព្រះអង្គជាមនុស្សដែលបានបំពេញខ្លួនឯងអោយមានលក្ខណះគ្រប់បរិបូរទាំងអស់។ យើងជឿថាមនុស្សលោកអាចដុះនូវអវិជ្ជានិងភាពគ្មានហេតុផលបានឆាប់រហ័ស ហើយឃើញវត្ថុគ្រប់យ៉ាងដូចដែលពួកគេឃើញថាពិតដូច្នោះ។ យើងជឿថាការប្រកាន់ខ្លួន សេចក្តីខឹង ការឈ្នានីស និងការច្រណែននិន្ទាអាចផ្លាស់ប្តូរបានដោយករុណាធម៏ ការអត់ធន់ ការទំនុកបំរុងគ្នា និងការមានសន្តានចិត្តល្អ។ យើងជឿថាទាំងអស់នេះគឺស្ថិតលើស្មារតីរបស់មនុស្សម្នាក់ៗប្រសិនបើគេមិនប្រមាទ ទាំងបានដឹកនាំនិងគាំទ្រដោយពុទ្ធបរិស័ទល្អៗទាំងឡាយ ហើយញ៉ាំងស្មារតីអោយយល់បានតាមពុទ្ធភាសិតដូចដែលព្រះពុទ្ធអង្គត្រាស់ថា " *មានតែខ្លួនជាទីពឹងនៃខ្លួន អ្នកដទៃមិនអាចជាទីពឹងដល់យើងបានឡើយ។ អ្នកត្រូវតែដើរនៅលើមាគ៌ាដោយខ្លួនឯង តថាគតគ្រាន់តែជាអ្នកចង្អុលបង្ហាញផ្លូវអោយដើរតែប៉ុណ្ណោះ*" ទីឃនិកាយ ១៦៥